បណ្ណព័ត៌មាន

# ការទិញនិងការចុះបញ្ជីលេខរថយន្ត

## មុនពេលទិញ

- លោកអ្នកគួរតែឆែកជាមួយនឹងសេវាស៊ើបសួរការចុះបញ្ជីលេខរថយន្តរបស់ VicRoads ។ សេវានេះផ្តល់ជូនដោយឥតគិតថ្លៃ ហើយអនុញ្ញាតឲ្យលោកអ្នកបញ្ជាក់អំពីស្ថានភាពនៃការចុះបញ្ជីលេខរថយន្ត ម៉ូតូ រថយន្តដឹកទំនិញ រ៉ឺម៉កសណ្តោង ខារ៉ាវ៉ាន នៅលើបញ្ជីលេខរថយន្តក្នុងរដ្ឋវិកថូរៀ។ ការសាកសួរសេវាស៊ើបសួរការចុះបញ្ជីលេខរថយន្ត នឹងអនុញ្ញាតឲ្យលោកអ្នកសុំព័ត៌មានអំពីថាតើលេខរថយន្តនេះនៅមានសុពលភាពឬទេ ហួសសុពលភាពឬយ៉ាងណា ត្រូវគេផ្អាកមិនឲ្យបើក ឬលប់ចោល។ លោកអ្នកក៏អាចសុំព័ត៌មានផងដែរអំពីរថយន្ត មានដូចជាលេខអត្តសញ្ញាណរថយន្ត លេខម៉ាស៊ីន ឬម៉ាករថយន្ត ពណ៌ ទ្រង់ទ្រាយ ឬឆ្នាំដែលផលិត ដើម្បីជួយលោកអ្នកក្នុងការពិនិត្យផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់រថយន្ត។ លោកអ្នកអាចឆែកជាមួយនឹងសេវាស៊ើបសួរការចុះបញ្ជីលេខរថយន្ត ដោយចូលទៅវ៉ិបសាយថ៍៖ **vicroads.vic.gov.au**
- លោកអ្នកក៏អាចឆែកបញ្ជីបំណុលទ្រព្យផ្ទាល់ខ្លួន (PPSR) ផងដែរ។ សេវានេះជាសេវាជាតិមួយដែលត្រូវបង់ថ្លៃ ប៉ុន្តែនឹងអនុញ្ញាតឲ្យលោកអ្នកឆែកព័ត៌មានរបស់រថយន្តណាមួយជាមុនសិន មុននឹងលោកអ្នកទិញ។ បើសិនជាលោកអ្នកទិញបណ្ណឆែកពិនិត្យបញ្ជីបំណុលទ្រពផ្ទាល់ខ្លួនណាមួយ លោកអ្នកអាចដឹង បើសិនជាមានការជំពាក់ប្រាក់ទៅលើរថយន្តនេះ (បន្ទុកផ្សេងៗទៅលើទ្រព្យ) ព័ត៌មានអំពីរថយន្ត (ម៉ាក និងម៉ូដែល) ស្ថានភាពលេខយានយន្ត ស្ថានភាពចោរកម្ម ឬស្ថានភាពលប់ចោល។ លោកអ្នកអាចឆែកជាមួយ PPSR ដោយទូរស័ព្ទទៅលេខ 1300 007 777 ឬឆែកវ៉ិបសាយថ៍៖ **ppsr.gov.au**

## ការទិញរថយន្តដែលមានបង់លេខរួចហើយ

### នៅពេលទិញរថយន្តដែលមានបង់លេខរួចហើយ លោកអ្នកត្រូវ៖

- សុំយកបណ្ណដែលមានសុពលភាពស្តីពីដំណើរការ និងស្ថានភាពរថយន្ត (Roadworthiness) ពីអ្នកលក់
- បំពេញទម្រង់នៃការដាក់ពាក្យសុំផ្ទេរលេខរថយន្តជាមួយនឹងអ្នកលក់។ ចូរទាញយកទម្រង់នេះចេញពីវ៉ិបសាយថ៍៖ **vicroads.vic.gov.au** ដោយទូរស័ព្ទទៅលេខ 13 11 71 ឬទៅយកនៅមណ្ឌលសេវាអតិថិជនរបស់ VicRoads ។

### ដើម្បីផ្ទេរលេខរថយន្តទៅឈ្មោះរបស់លោកអ្នក

- ដាក់ទម្រង់ពាក្យសុំផ្ទេរដែលបំពេញរួចហើយ បណ្ណបញ្ជាក់ពីដំណើរការនិងស្ថានភាពរថយន្ត(Roadworthiness) និងប្រាក់ថ្លៃឈ្នួលទៅ VicRoads នៅក្នុងរវាងពេល 14 ថ្ងៃនៃការលក់ដូររួច។ លោកអ្នកអាចធ្វើការងារនេះដោយផ្ញើឯកសារដែលត្រូវការទាំងអស់នោះ និងប្រាក់ថ្លៃឈ្នួល ទៅ VicRoads, GPO Box 1644, Melbourne 3001, ឬក៏អញ្ជើញទៅជួបមណ្ឌលសេវាអតិថិជនរបស់ VicRoads ដោយផ្ទាល់តែម្តង។
- នៅពេលដែលទិញរថយន្តពីកន្លែងលក់រថយន្ត ក្រុមហ៊ុនលក់រថយន្តនឹងបញ្ជូនឯកសារដែលត្រូវការទាំងនោះទៅ VicRoads ។

### ថ្លៃឈ្នួល

- ថ្លៃឈ្នួលសម្រាប់ការផ្ទេររថយន្ត
- ថ្លៃពន្ធរថយន្ត

ថ្លៃឈ្នួលអាចគណនាតាមអ៊ិនធើរណិតបានតាមវ៉ិបសាយថ៍៖ **vicroads.vic.gov.au** ឬទូរស័ព្ទទៅលេខ 13 11 71 ។

**បណ្ណបញ្ជាក់ពីដំណើរការនិងស្ថានភាពរថយន្ត (Certificate of Roadworthiness)**

- គឺត្រូវការចាំបាច់នៅពេលដែលមានការលក់រថយន្តដែលមានលេខ ឬនៅពេលដែលរថយន្តដែលធ្លាប់ប្រើត្រូវចុះឈ្មោះយកលេខរថយន្តឡើងវិញ។
- អាចចេញឲ្យបានដោយអ្នកធ្វើតេស្តរថយន្តដែលមានអាជ្ញាបណ្ណ ចេញពី VicRoads ប៉ុណ្ណោះ ។
- គឺជាការឆែកពិនិត្យរថយន្តដើម្បីធានាថារថយន្តនេះមានសុវត្ថិភាពក្នុងការបើកបរបាន។
- មិនមានន័យថា រថយន្តនេះឋិតនៅក្នុងស្ថានភាពល្អឥតទាស់នោះទេ ពោលគឺរថយន្តអាចមានការខូចខ្លះ តែផ្នែកដែលខូចនោះមិនប៉ះពាល់ដល់សុវត្ថិភាពសម្រាប់ការបើកបរឡើយ។
- មានសុពលភាពតែ 30 ថ្ងៃទេ ចាប់ពីថ្ងៃដែលចេញបណ្ណនោះ។

## ការទិញរថយន្តដែលគ្មានលេខ

### នៅពេលដែលទិញរថយន្តដែលគ្មានលេខ លោកអ្នកត្រូវតែ៖

- យកវិក្កយបត្រដែលមានដាក់ថ្ងៃខែឆ្នាំ និងហត្ថលេខាពីអ្នកលក់។ វិក្កយបត្រនោះត្រូវមានម៉ាករថយន្ត ម៉ូដែល និងលេខអត្តសញ្ញាណរថយន្ត (VIN) រួមទាំងឈ្មោះនិងអាសយដ្ឋានរបស់លោកអ្នក និងអ្នកលក់ផងដែរ
- ទាក់ទងសុំយកលិខិតអនុញ្ញាតមួយសម្រាប់បើករថយន្តដែលគ្មានលេខ។
- យករថយន្តទៅឆែកពិនិត្យយកបណ្ណបញ្ជាក់ពីដំណើរការ និងស្ថានភាពរថយន្ត(Certificate of Roadworthiness)
- ផ្តល់ឯកសារភស្តុងតាងបង្ហាញលេខចាស់របស់រថយន្ត មានដូចជាបណ្ណចុះបញ្ជីយកលេខរថយន្តពីមុខ។
- ធ្វើការណាត់ជួបដើម្បីចុះបញ្ជីយកលេខរថយន្ត ហើយនាំយករថយន្តឲ្យគេពិនិត្យនៅមណ្ឌលសេវាអតិថិជនរបស់ VicRoads (លោកអ្នកត្រូវតែមានអាយុយ៉ាងតិច 17 ឆ្នាំ នៅពេលធ្វើការចុះបញ្ជីយកលេខរថយន្ត)

#### លិខិតអនុញ្ញាតឲ្យបើករថយន្តដែលគ្មានលេខ

មុននឹងបើករថយន្តដែលគ្មានលេខ យកទៅជួសជុល ឬធ្វើតេស្តយកបណ្ណបញ្ជាក់ពីដំណើរការ និងស្ថានភាពរថយន្ត លោកអ្នកត្រូវតែសុំលិខិតអនុញ្ញាតឲ្យបើករថយន្តដែលមានគ្មានលេខ ៖

- លិខិតនេះអនុញ្ញាតឲ្យលោកអ្នកបើករថយន្តនោះនៅតាមផ្លូវ ដើម្បីទៅសុំបណ្ណបញ្ជាក់ពីដំណើរការ និងស្ថានភាពរថយន្ត និងដើម្បីរៀបចំរថយន្ត ទៅចុះបញ្ជីយកលេខ។
- លិខិតនេះអាចទិញបានដោយទូរស័ព្ទទៅ VicRoads តាមរយៈលេខ 13 11 71 ឬពីមណ្ឌលសេវាអតិថិជនរបស់ VicRoads ។ លោកអ្នកត្រូវរៀបរាប់ប្រាប់ អំពីរថយន្តដោយត្រូវផ្តល់លេខក្បាលម៉ាស៊ីន ឬលេខអត្តសញ្ញាណរថយន្ត (VIN)។
- ការបើករថយន្តគ្មានលេខដោយពុំមានលិខិតអនុញ្ញាតឲ្យបើករថយន្តគ្មានលេខគឺជាបទល្មើសច្បាប់ លើកលែងតែលោកអ្នកមានការណាត់ជួបជាមួយនឹង VicRoads ហើយត្រូវបើករថយន្តទៅទីនោះដើម្បីចុះបញ្ជីយកលេខរថយន្តប៉ុណ្ណោះ។

## ដើម្បីចុះឈ្មោះយកលេខរថយន្ត លោកអ្នកត្រូវតែ៖

### ធ្វើការណាត់ជួប៖

- ទូរស័ព្ទទៅ VicRoads តាមលេខ 13 11 71(ការបង់ថ្លៃឈ្នួលអាចធ្វើបានតាមរយៈតែ Visa Card ឬ Master Card ប៉ុណ្ណោះ) ឬអញ្ជើញទៅមណ្ឌលសេវាអតិថិជនរបស់ VicRoads (ការបង់ថ្លៃអាចធ្វើបានដោយសាច់ប្រាក់សុទ្ធ, មូលប្បទានបត្រ, EFTPOS, Visa Card ឬ Master Card) ដើម្បីធ្វើការណាត់ជួប ហើយបង់ថ្លៃការណាត់ជួបនោះ។
- នៅពេលដែលធ្វើការណាត់ជួប លោកអ្នកនឹងត្រូវការលេខអត្តសញ្ញាណរថយន្ត (VIN) លេខក្បាលម៉ាស៊ីនរថយន្ត និងផ្លាកលេខរថយន្ត(បើសិនជាមាន)។

### នៅពេលទៅជួបតាមការណាត់៖

- នាំយករថយន្តទៅជាមួយដើម្បីការឆែកពិនិត្យ។
- ផ្តល់បណ្ណបញ្ជាក់ពីដំណើរការ និងស្ថានភាពរថយន្ត ដែលមានសុពលភាព។
- ផ្តល់ឯកសារភស្តុតាងបញ្ជាក់ពីអត្តសញ្ញាណរបស់លោកអ្នក (អាជ្ញាបណ្ណបើកបររថយន្តគឺជាអ្វីដែលគេត្រូវការចាំបាច់, ឬ លោកអ្នកត្រូវបង្ហាញឯកសារមួយចំនួនដែលជាភស្តុតាងបញ្ជាក់នូវអត្តសញ្ញាណ បើសិនជាគ្មានអាជ្ញាបណ្ណបើកបរ)។
- យកមកជាមួយនូវវិក្កយបត្របញ្ជាក់ពីការទិញដូរដើម្បីបង្ហាញថាលោកអ្នកអាចចុះបញ្ជីសុំលេខរថយន្តតាមផ្លូវច្បាប់។
- ផ្តល់ដំណឹងឲ្យ VicRoads ដឹង បើសិនជាលោកអ្នកមានបណ្ណសម្បទាន (concession card)។
- បង់ថ្លៃឈ្នួល។

### ថ្លៃឈ្នួល៖

- ថ្លៃចុះបញ្ជីយកលេខរថយន្ត (ដោយមានការបញ្ចុះថ្លៃសម្រាប់អត្រាបណ្ណសម្បទានគឺមានជូន)
- ថ្លៃឈ្នួលសម្រាប់ការផ្តល់ផ្លាកលេខរថយន្ត(បើសិនជាត្រូវការ)
- ថ្លៃសម្រាប់ការឆែកពិនិត្យ (បើសិនជាត្រូវការ ជាទូទៅបង់នៅពេលដែលធ្វើការណាត់ជួប)
- ថ្លៃឈ្នួលគណៈកម្មាធិការគ្រោះថ្នាក់ដោយយានយន្តដឹកជញ្ជូន (ចាំបាច់ត្រូវបង់ការធានារ៉ាប់រង ភាគីទីបីសម្រាប់គ្រោះមានរបួសដល់មនុស្ស- compulsory third party personal injury insurance)
- ថ្លៃពន្ធរថយន្ត។

លោកអ្នកអាចធ្វើការគណនាថ្លៃឈ្នួល និងចំណាយទាំងឡាយបានតាមរយៈ វិបសាយថ៍ **vicroads.vic.gov.au** ឬទូរស័ព្ទទៅលេខ៖13 11 71។

សម្រាប់ព័ត៌មានបន្ថែម សូមបើកមើលវិបសាយថ៍ **vicroads.vic.gov.au** ឬទូរស័ព្ទទៅលេខ៖ **13 11 71** ឬ អញ្ជើញទៅជួបមណ្ឌលសេវាអតិថិជនរបស់ VicRoads ។

ព័ត៌មានដែលផ្តល់ជូននៅក្នុងបណ្ណព័ត៌មាននេះ គឺត្រឹមត្រូវនៅពេលបោះពុម្ពផ្សាយ ហើយខ្លឹមសារនៃព័ត៌មាននេះអាចមានការផ្លាស់ប្តូរ។

VRPIN02900 Buying and Registering a Car – Khmer Authorised by VicRoads, 60 Denmark Street, Kew, 3101